DECENT WORK
A better world starts here.

International Labour Organization

សេចក្តីប្រកាសព័ត៌មាន

# “គ្មាននរណាម្នាក់ គួរធ្វើការរបៀបនេះទេ” - ការតាំងពិពណ៌រូបថតរបស់លោក STEVE MCCURRY នៅអេហ្វ ស៊ី ស៊ី ស្តីពីការឆ្លុះបញ្ចាំងពីការរំលោភបំពាន អ្នកបម្រើការងារតាមផ្ទះ

**សម្រាប់ការផ្សាយបន្ទាន់៖ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៥**

ភ្នំពេញ– (ពត៌មានរបស់អង្គការអន្តរជាតិខាងការងារ) រូបថតស្តីពីការរំលោភបំពានអ្នកបម្រើការងារតាមផ្ទះ ដែលថតដោយអ្នកថតរូបដ៏ល្បីល្បាញ គឺលោក Steve McCurry នឹងត្រូវបានដាក់តាំងពិពណ៌នៅឯអេហ្វ ស៊ី ស៊ី ក្រុងភ្នំពេញ ប្រទេសកម្ពុជា នៅក្នុងកំឡុងខែឧសភាខាងមុខនេះ។

លើសពីនេះ បទបង្ហាញ និងកិច្ចពិភាក្សាស្តីពីពិពណ៌រូបថត ព្រមទាំងបញ្ហាដែលពួកគេបានលើកឡើង នឹងធ្វើឡើងនៅថ្ងៃព្រហស្បតិ៍ ទី០៧ ខែឧសភា។

ការតាំងពិពណ៌, “គ្មាននរណាម្នាក់ គួរធ្វើការរបៀបនេះទេ៖ ការទប់ស្កាត់ការរំលោភបំពាន អ្នកបម្រើការងារតាមផ្ទះ,” ឆ្លុះបញ្ចាំងអំពីរូបថតអ្នកបម្រើការងារតាមផ្ទះ ដែលត្រូវបានរំលោភបំពានទាំងផ្លូវកាយ និងផ្លូវចិត្ត ពីសំណាក់និយោជករបស់ពួកគេ។

រូបថតទាំងនេះ គឺជាផលិតផលរបស់គម្រោងរយៈពេល១៨ខែ ដែលថតដោយលោក Steve McCurry និង Karen Emmons ដែលអ្នកទាំងពីរជាអ្នកការសែតមានមូលដ្ឋាននៅឯប្រទេសថៃ គឺដើម្បីលើកកម្ពស់ការយល់ដឹង នៃការរំលោភបំពាន ដែលអ្នកបម្រើការងារតាមផ្ទះស៊ូទ្រាំ និងជម្រុញរាជរដ្ឋាភិបាល ព្រមទាំងសង្គមដោះស្រាយបញ្ហានេះ។ តាមរយៈការធ្វើការសង្គមដោយស្ម័គ្រចិត្ត អ្នកទាំងពីរ បានសំភាសន៍ និងថតរូបអ្នកបម្រើការងារតាមផ្ទះ នៅក្រុងហុងកុងស ប្រទេសឥណ្ឌូនេស៊ី នេប៉ាល់ និងហ្វីលីពីន។ ពួកគេ បានរកឃើញពីការរំលោភបំពាន ទាំងផ្នែកផ្លូវកាយ និងផ្លូវចិត្ត ពលកម្មកុមារ ការងារបង្ខំ ការជួញដូរមនុស្ស ការរំលោភ សេចក្តីអត់ឃ្លាន ការមិនផ្តល់ប្រាក់ឈ្នួល និងការរឹតបន្តឹងការធ្វើដំណើរ និងការទំនាក់ទំនង។

លោក Steve McCurry គឺល្បីល្បាញតាមរយៈ ស្នាដៃរូបថតរបស់លោក អំពីជនភៀសខ្លួនវ័យក្មេង ដែលត្រូវបានស្គាល់ថា “ក្មេងស្រីអាហ្វហ្គានីស្ថាន” ដែលត្រូវបានដាក់នៅក្របទំព័រមុខ នៃទស្សនាវដ្តីភូមិសាស្ត្រជាតិ។ លោកបានទទួលពានរង្វាន់ជាច្រើន រួមទាំងពានរង្វាន់អ្នកថតរូបសារព័ត៌មានថ្នាក់ជាតិ ចំនួន៤ដង ពានរង្វាន់ Olivier Rebbot ចំនួន២ដង មេដាយមាស Robert Capa មេដាយ Centenaryសម្រាប់សមិទ្ធិផលមួយជីវិត និងអ្នកថតរូបទស្សនាវដ្តីឆ្នើមប្រចាំឆ្នាំ។

លោកស្រី Karen Emmons ជាអ្នកកាសែតអាមេរិច ដែលរស់នៅ និងបម្រើការងារក្នុងតំបន់អាស៊ី អស់រយៈពេល២៥ឆ្នាំ។ អត្ថបទរបស់នាង បានចុះផ្សាយនៅស្ថាប័នបោះពុម្ពជាច្រើន រួមទាំងទស្សនាវដ្តី LIFE, Far Eastern Economic Review, Time, People, Reader’s Digest, The South China Morning Post, International Herald Tribune និង London Sunday Times.

គម្រោងការតស៊ូមតិនេះ គឺត្រូវបានផ្តល់មូលនិធិដោយការិយាល័យប្រចាំតំបន់ នៃអង្គការអន្តរជាតិខាងការងារក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ អង្គការអន្តរជាតិខាងការងារ ប៉ាន់ប្រមាណថា មានអ្នកបម្រើការងារតាមផ្ទះលើសពី៥២លាននាក់



ILO Regional Office for Asia and the Pacific
United Nations Building, 11th Floor
Rajdamnern Nok Avenue
Bangkok 10200, Thailand

Tel. +66 2 288 1234
Fax. +66 2 288 3062
Email: bangkok@ilo.org
www.ilo.org/asia

For information only. Not an official record.

DECENT WORK
A better world starts here.

International Labour Organization

សេចក្តីប្រកាសព័ត៌មាន

នៅក្នុងពិភពលោកនេះ ដែលពួកគេភាគច្រើនកង្វះ សូម្បីតែការការពារសិទ្ធិមូលដ្ឋាន។ នៅឆ្នាំ ២០១១ អនុសញ្ញាថ្មីរបស់ អង្គការអន្តរជាតិខាងការងារ ដែលផ្តោតជាពិសេសលើសិទ្ធិអ្នកបម្រើការងារតាមផ្ទះ បានចូលជាធរមានរួចហើយ តែរហូតមកដល់ពេលនេះ វាត្រូវបានផ្តល់សច្ចាប័នតែប្រទេសចំនួន១៧ប៉ុណ្ណោះ។

ពិធីបើកការតាំងពិពណ៌រូបថតនេះ នឹងធ្វើឡើងនៅថ្ងៃព្រហស្បត៍ ទី០៧ ខែឧសភា វេលាម៉ោង៦ និង៣០នាទីល្ងាច។ លោកស្រី Emmons នឹងនិយាយអំពីគម្រោងនេះ ព្រមទាំងអ្នកបម្រើតាមផ្ទះ ដែលពួកគេបានជួប ខណៈដែលអ្នកជំនាញអង្គការអន្តរជាតិខាងការងារ នឹងបកស្រាយបន្ថែម អំពីបញ្ហាទូលំទូលាយជាងនេះ។ ដោយឡែកការតាំងពិពណ៌រូបថត នឹងធ្វើឡើងរហូតដល់ ថ្ងៃអាទិត្យ ទី០៧ ខែមិថុនា។ អេហ្វ ស៊ី ស៊ី គឺចាប់បើកពីម៉ោង ៧ព្រឹកដល់ពាក់កណ្តាលយប់។ ការចូលរួមទស្សនាគឺមិនគិតថ្លៃទេ។ អេហ្វ ស៊ី ស៊ី ភ្នំពេញ គឺអាចរកឃើញ តាមរយៈអាស័យដ្ឋាន៖ ផ្លូវ៣៦៣ មហាវិថី ព្រះស៊ីសុវត្ថិ ភ្នំពេញ ប្រទេសកម្ពុជា។

សម្រាប់ពត៌មានបន្ថែម សូមចូល www.ilo.org/asia ឬ www.facebook.com/events/1412855132354505/ ឬទំនាក់ទំនង៖


**Sophy Fisher**
ការិយាល័យប្រចាំតំបន់ នៃអង្គការអន្តរជាតិខាងការងារក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក - ទីក្រុងបាងកក
ទូរសព្ទ៖ +៥៦៦ ២ (0) ២២៨៨ ២៥៨៥
fisher@ilo.org

**អេហ្វ ស៊ី ស៊ី ភ្នំពេញ**
ទូរសព្ទ៖ ៨៥៥ ៧២៤ ០១៥
phnompenh@fcchotels.com